**ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់**
**ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក៖**
**ការអភិវឌ្ឍជើងឯកផ្នែកនីតិបរិស្ថាន**
**កម្មវិធីការបណ្តុះបណ្តាលគ្រូបង្គោល**
**ថ្ងៃទី ២៧ ខែ វិច្ឆិកា - ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧**
**ខេត្តសៀមរាប ប្រទេសកម្ពុជា**

## ករណីសិក្សាប្រឌិតសម្រាប់ការពិភាក្សាក្រុមតូច (វគ្គទី ៤-៧)

១. ក្រុមហ៊ុនមីលគីវ៉េលីមីតធីត គឺជាក្រុមហ៊ុនឯកជនមានកម្រិតកំណត់បានចុះបញ្ជីស្របច្បាប់ក្នុងប្រទេសរបស់អ្នក [កម្ពុជា ឬប្រជាធិបតេយ្យឡាវ]។ ក្រុមហ៊ុនបានផលិតគ្រឿងសង្ហារឹមអស់ពេលជាច្រើនឆ្នាំមកហើយ ហើយមានកេរ្តិ៍ឈ្មោះល្អនៅក្នុងប្រទេស។

២. ក្រុមហ៊ុនមីលគីវ៉េលីមីតធីត មានបំណងចង់ពង្រីកអាជីវកម្មរបស់ខ្លួនចូលទៅក្នុងវិស័យទេសចរណ៍។ ក្រុមហ៊ុនគ្រោងអភិវឌ្ឍសណ្ឋាគារ និងកន្លែងកំសាន្តទេសចរណ៍នៅក្នុងតំបន់ការពារមួយក្នុងប្រទេសរបស់អ្នក។ ក្រុមហ៊ុនបានដាក់សំណើវិនិយោគមកកាន់រដ្ឋាភិបាលរបស់អ្នកដើម្បីជួលដីក្នុងបរិវេណមួយ ទំហំ ២០០០ ហិកតា ក្នុងតំបន់ការពាររយៈពេល ៥០ ឆ្នាំ។

៣. តំបន់ការពារត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកាលពី ១៥ ឆ្នាំមុន ហើយមានទំហំជាង ៦៥០០០ ហិចតា។ ក្នុងតំបន់អភិរក្សមានប្រជាជនជនជាតិដើមភាគតិចដែលបានរស់នៅទីនោះអស់ជាច្រើនជំនាន់មកហើយ ហើយពឹងផ្អែកលើធនធានធម្មជាតិពីព្រៃនោះ។ ពុំមានផ្លូវចាក់កៅស៊ូ ប្រព័ន្ធទឹកស្អាត ឬអគ្គិសនីទេនាពេលបច្ចុប្បន្នក្នុងតំបន់ការពារ។ ទោះយ៉ាងណាក្តី អ្នកទេសចរណ៍ក្នុងស្រុក និងបរទេសមួយចំនួនមកទស្សនាតំបន់ការពារ ដើម្បីរីករាយជាមួយធម្មជាតិ និងរៀនសូត្រអំពីវប្បធម៌ និងជីវិតជនជាតិដើមភាគតិច។

៤. យោងតាមសំណើវិនិយោគរបស់ក្រុមហ៊ុន ក្រុមហ៊ុននឹងឈូសឆាយដីក្នុងបរិវេណ ២០០០ ហិចតា ក្នុងតំបន់ការពារ ដើម្បីសាងសង់រមណីយដ្ឋានដែលអាចបម្រើដល់អ្នកទេសចរណ៍ក្នុងស្រុក និងអ្នកទេសចរណ៍បរទេស។ មានទីតាំងជាច្រើនដែលមានសារៈសំខាន់ផ្នែកវប្បធម៌សម្រាប់ជនជាតិដើមភាគតិចតាំងនៅក្នុងតំបន់នេះ រួមទាំងព្រៃដូនតាផងដែរ។ តំបន់អភិវឌ្ឍរួមមានពួជសត្វស្វា langur ជិតផុតពូជសម្រាប់បង្កាត់ពូជជាច្រើនគូ ហើយមានជម្រកនៃពូជរុក្ខជាតិក្នុងស្រុក។ ការអភិវឌ្ឍរមណីយដ្ឋាននេះនឹងរួមមានដូចខាងក្រោម៖

- សណ្ឋាគារមួយដែលអាចទទួលភ្ញៀវ ១០០០ នាក់។

- ទីលានវាយកូនហ្គោល និងផ្ទៃទឹក និងស្រះជាច្រើន។
- ភោជនីយដ្ឋានជាច្រើន។
- រោងចក្រសម្រាប់ទាញយកទឹកពីក្រោមដី។
- ផ្លូវថ្មីមួយដែលអនុញ្ញាតឱ្យភ្ញៀវអាចមកកាន់រមណីដ្ឋានបាន។
- បណ្ដាញអគ្គិសនីដើម្បីនាំអគ្គិសនីមកកាន់រមណីយដ្ឋាន។
- បរិក្ខារប្រព្រឹត្តិកម្មទឹកកខ្វក់។

៥. ក្រុមហ៊ុនសន្យាអនុវត្តតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធរបស់ប្រទេស គោរពវប្បធម៌ និងប្រពៃណីមូលដ្ឋាន បង្កើតការងារ និងលើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុក។ សំណើវិនិយោគអះអាងថា ការវិនិយោគនេះក៏អនុលោមតាមគោលនយោបាយជាតិ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលស្ដីពីការលើកកម្ពស់ទេសចរណ៍ផងដែរ។

៦. មានការប្រឆាំងមួយចំនួនត្រូវបានលើកឡើងរួចជាស្រេចទៅហើយចំពោះសំណើនេះ។ NGO បរិស្ថានជាច្រើនបានចេញសេចក្ដីថ្លែងការណ៍រួមបង្ហាញកង្វល់របស់ខ្លួនថា សណ្ឋាគារ និងរមណីយដ្ឋាននេះនឹងមានផលប៉ះពាល់ផ្នែកបរិស្ថានគួរជាទីកត់សម្គាល់មួយចំនួននៅក្នុងតំបន់ការពារ រួមទាំងការបំផ្លាញជម្រកបង្កើនហានិភ័យកាន់តែច្រើនសម្រាប់ការចាប់យកសត្វព្រៃ ការបោះចោលទឹកកខ្វក់ ការប្រើប្រាស់ទឹកក្រោមដីហួសប្រមាណ និងការបំផ្លាញទីតាំងមានសារៈសំខាន់ផ្នែកវប្បធម៌។ បន្ថែមលើនេះទៀត សហគមន៍ជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងតំបន់ការពារបានត្អូញត្អែរថា ពួកគេអាចនឹងជួបផលប៉ះពាល់ផ្នែកសង្គម ជាលទ្ធផលកើតចេញពីគម្រោង រួមទាំងការរំខានទ្រង់ទ្រាយធំមកលើបែបបទជីវិតតាមបែបប្រពៃណីរបស់ពួកគេ និងលទ្ធភាពកាន់តែតិចដើម្បីចូលទៅរកធនធានធម្មជាតិដែលពួកគេត្រូវអាស្រ័យផល។

៧. ឧបមាថា អ្នកគឺជាមន្ត្រីផ្នែកច្បាប់របស់រដ្ឋាភិបាលកំពុងធ្វើការក្នុងក្រសួង ដែលសំណើវិនិយោគរបស់ក្រុមហ៊ុននេះត្រូវបានបញ្ជូនមកនៅជំហានដំបូងដោយរដ្ឋាភិបាល។ អ្នកបានទទួលការស្នើសុំឱ្យធ្វើការជាមួយក្រុមការងារអន្តរក្រសួង ដែលចាំបាច់ត្រូវផ្ដល់យោបល់ដល់រដ្ឋាភិបាលថា តើរដ្ឋាភិបាលគួរអនុម័តលើសំណើអាជីវកម្មនេះ ឬទេ។ ការទទួលខុសត្រូវជាក់លាក់របស់អ្នក គឺត្រូវផ្ដល់ព័ត៌មានដល់ក្រុមការងារអន្តរក្រសួងអំពីការតម្រូវផ្នែកច្បាប់ កើតចេញពីច្បាប់បរិស្ថានដែលត្រូវអនុវត្តចំពោះគម្រោងនេះ។

**សំណួរ៖**

១. ចំពោះវគ្គទី ៤ តែប៉ុណ្ណោះ៖ តើអ្វីខ្លះជាផលប៉ះពាល់ផ្នែកបរិស្ថាន និងផ្នែកសង្គមសំខាន់ៗដែលអាចកើតចេញពីគម្រោងនេះ?

២. វគ្គទី ៤-៧៖ តើច្បាប់ និងបទបញ្ញត្តិណាខ្លះពាក់ព័ន្ធជាមួយនឹងប្រធានបទនៃវគ្គសិក្សានេះដែលត្រូវអនុវត្តចំពោះសំណើគម្រោង?

៣. វគ្គ ៤-៧៖ តើក្រសួង/ស្ថាប័នរដ្ឋាភិបាលណាខ្លះដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ?

៤. ចំពោះវគ្គទី ៧ ប៉ុណ្ណោះ៖ តើដំបូន្មានអ្វីខ្លះដែលអ្នកអាចផ្តល់ដល់ក្រុមការងារអន្តរក្រសួងទាក់ទងជាមួយថាតើរដ្ឋាភិបាលគួរអនុម័តលើសំណើនេះ ឬទេ?